00381115

E170

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de première instance

សំណុំរឿងលេខ: ០០១/១៨ កក្កដា ២០០៧-អវតក/អជសដ
**Case File/Dossier No. 001/18-07-2007-ECCC/TC**

| | |
|---|---|
| ចំពោះមុខ: | ចៅក្រម **និល ណុន** ជាប្រធាន |
| | ចៅក្រម Silvia CARTWRIGHT |
| | ចៅក្រម **យ៉ា សុខន** |
| | ចៅក្រម Jean-Marc LAVERGNE |
| | ចៅក្រម **ធូ មណី** |
| កាលបរិច្ឆេទ: | ថ្ងៃទី ៣០ ខែកញ្ញា ឆ្នាំ២០០៩ |
| ចំណាត់ថ្នាក់ឯកសារ: | សាធារណៈ |

**ឯកសារដើម**
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 30 / 09 / 2009
ម៉ោង (Time/Heure): 15:25
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

**ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម**
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 30 / 09 / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

---

# ដីកាកំណត់កាលវិភាគសម្រាប់ភាគីធ្វើសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល

---

**សហព្រះរាជអាជ្ញា**

ជា លាង
William SMITH (ស្តីទី)

**ជនជាប់ចោទ**

កាំង ហ្គេកអ៊ាវ ហៅ ឌុច

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

គង់ ពិសី
ហុង គឹមសួន
យុង ផានិត
គឹម ម៉េងឃី
ម៉ុច សុវណ្ណារី
Silke STUDZINSKY
Martine JACQUIN
Philippe CANONNE

ទី ស្រ៊ីណា
Pierre Olivier SUR
Alain WERNER
Brianne McGONIGLE
Annie DELAHAIE
Elizabeth RABESANDRATANA
Karim KHAN
Fabienne TRUSSES-NAPROUS
Christine MARTINEAU

**មេធាវីជនជាប់ចោទ**

ការ សាវុត្ថ
François ROUX
Marie-Paule CANIZARÈS

E170

០០១/១៨ កក្កដា ២០០៧/អវតក/អជសង

**អង្គជំនុំជម្រះសាលាដំបូង** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក")

**បានឃើញ** សេចក្តីណែនាំស្តីពីនីតិវិធីពាក់ព័ន្ធនឹងការទាមទារសំណង និងការដាក់សេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរបញ្ចប់ការពិភាក្សាដេញដោល ចុះថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០០៩ (ឯកសារ E159)។

**បានឃើញ** វិធាន៩៤ នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក។

**ក្រោយពីបាន** ពិនិត្យមើលសំណើរបស់ភាគីស្តីពីការស្នើសុំពេលវេលាដើម្បីធ្វើសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលរួចមក។

**ចេញដីកាកំណត់កាលវិភាគដូចខាងក្រោម៖**

១. ភាគីទាំងអស់នៃរឿងក្តីត្រូវធ្វើសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលរបស់ខ្លួនទៅតាមពេលវេលាដែលបានកំណត់ដោយអង្គជំនុំជម្រះដូចខាងក្រោម៖

ក. ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ ត្រូវធ្វើសេចក្តីសន្និដ្ឋានបញ្ចប់តាមរយៈមេធាវីតំណាងរបស់ខ្លួននៅថ្ងៃទី ២៣ ខែវិច្ឆិកា ឆ្នាំ ២០០៩ (រយៈពេលដែលផ្តល់ជូនគឺ ៥ ម៉ោង)។

ខ. សហព្រះរាជអាជ្ញាត្រូវធ្វើសេចក្តីសន្និដ្ឋានបញ្ចប់នៅថ្ងៃទី ២៤ ខែវិច្ឆិកា ឆ្នាំ ២០០៩ (រយៈពេលដែលផ្តល់ជូនគឺ ៥ ម៉ោង)។

គ. ក្រុមមេធាវីការពារក្តី និងជនជាប់ចោទត្រូវធ្វើសេចក្តីសន្និដ្ឋានបញ្ចប់នៅថ្ងៃទី ២៥ និងព្រឹកថ្ងៃទី ២៦ ខែវិច្ឆិកា ឆ្នាំ ២០០៩ (រយៈពេលដែលផ្តល់ជូនគឺ ៧ម៉ោង និង ៣០ នាទី)។



TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE
E C C C • E T C

E170

០០១/១៨ កក្កដា ២០០៧/អវតក/អជសង

២. បន្ទាប់ពីធ្វើសេចក្តីសន្និដ្ឋានបញ្ចប់របស់មេធាវីការពារក្តី និងជនជាប់ចោទ អង្គជំនុំជម្រះនឹងផ្តល់រយៈពេលយ៉ាងយូរត្រឹម ១ ម៉ោង សម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី និងយ៉ាងយូររយៈពេល ១ ម៉ោង សម្រាប់សហព្រះរាជអាជ្ញា ក្នុងការធ្វើសេចក្តីសន្និដ្ឋានតបវិញ ប្រសិនបើពួកគេមានបំណងធ្វើដូច្នេះ។

៣. នៅចុងបញ្ចប់ អង្គជំនុំជម្រះនឹងផ្តល់ពេលវេលាសម្រាប់មេធាវីការពារក្តី និង/ឬ ជនជាប់ចោទ យ៉ាងយូរត្រឹមរយៈពេល ១ ម៉ោង ដើម្បីធ្វើសេចក្តីសន្និដ្ឋានចុងក្រោយ។

៤. សវនាការស្តាប់សេចក្តីសន្និដ្ឋានរបស់ភាគីនឹងត្រូវបញ្ចប់នៅថ្ងៃសុក្រ ទី ២៧ ខែវិច្ឆិកា ឆ្នាំ ២០០៩ នៅម៉ោង ៣.៣០ នាទី។

នៅក្នុងអំឡុងពេលសវនាការនៃស្តាប់សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល អង្គជំនុំជម្រះនឹងធ្វើការពិចារណាទៅលើការស្នើសុំពេលវេលាបន្ថែមរបស់មេធាវីការពារក្តី ប្រសិនបើសំណើនោះត្រូវបានស្នើឡើងដោយមានហេតុផលសមស្រប។

ភ្នំពេញ ថ្ងៃទី ៣០ ខែកញ្ញា ឆ្នាំ២០០៩

ប្រធានអង្គជំនុំជម្រះសាលាដំបូង

និល ណុន